ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

# សាលាបឋមសិក្សា សោថហ្វក (Southwark)

*"ទោះជាភាសាអ្វីក៏ដោយ ការញញឹមគឺដូចគ្នាទាំងអស់"*

**Mr. Andrew Lukov**, *នាយកសាលា*

1835 South 9th Street Philadelphia, PA 19148
ទូរស័ព្ទ៖ ២១៥-៩៥២-៨៦០៦ ទូរសារ៖ ២១៥-៩៥២-៨៦៧០

## ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស របស់សាលាបឋមសិក្សា សោថហ្វក

សាលា សោថហ្វក មានជំនឿថា មធ្យោបាយដ៏ល្អបំផុតដើម្បីទប់ស្កាត់បញ្ហាដាក់ទណ្ឌកម្ម គឺធ្វើឲ្យមានបរិយាកាសល្អ និងមានការគាំទ្រ នៅសាលា និងកម្មវិធីបង្ហាត់បង្រៀនដែលធ្វើឲ្យសិស្សានុសិស្សចូលរួមយ៉ាងសកម្មគ្រប់ពេលវេលា។ គ្រូបង្រៀនរបស់យើងបានសច្ចាថានឹងផ្តល់បរិយាកាសបែបនេះដល់កូនរបស់លោកអ្នកទាំងអស់។ ព័ត៌មានអំពីក្រមសីលធម៌ខាងក្រោមនេះនឹងត្រូវអនុវត្តនៅពេលណាសិស្សមានអាកប្បកិរិយារំខាន។ យើងខ្ញុំសុំឲ្យ មាតាបិតា/អាណាព្យាបាល រួមសហការជាមួយយើងខ្ញុំ ក្នុងការគោរពតាមក្រមសីលធម៌នេះ។ យើងនឹងផ្តល់យុត្តិធម៌ និងមានការស្មោះត្រង់ចំពោះសិស្សទាំងអស់។

**បទល្មើសកម្រិត ១**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា បានចាត់ទុកអាកប្បកិរិយារំខានខាងក្រោមនេះ ថាជាបទល្មើសកម្រិត១៖

- *មិនធ្វើតាមវិន័យរបស់ថ្នាក់ / រំខាន*
- *សម្លៀកបំពាក់មិនសមរម្យ*
- *មិនកាន់ស្លាកដើរក្នុងអាគារសាលា / គ្មានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ*
- *មិនចូលរួមជាមួយសកម្មភាពនៅក្នុងថ្នាក់ / គ្មានការត្រៀមខ្លួនដើម្បីរៀនសូត្រ*
- *គេចមិនមករៀន / មករៀនយឺតពេលជាញឹកញាប់ / គេចមិនចូលថ្នាក់រៀន*
- *មានរបស់ផ្ទាល់ខ្លួនដែលមិនសមរម្យ*
- *ប្រើពាក្យ ឬកាយវិការដែល ប្រមាថមើលងាយ / អាសអាភាស*

វិធីសាស្ត្រដែលគេបានយល់ព្រមសម្រាប់ថ្នាក់ទាប៖

ចំពោះការល្មើសច្បាប់អ្វីមួយនៃ បទល្មើសកម្រិត១ គ្រូត្រូវធ្វើតាមវិធីដាក់ទណ្ឌកម្មតាមលំដាប់ដូចតទៅ ដើម្បីដោះស្រាយអាកប្បកិរិយាដែលសិស្សបានប្រព្រឹត្ត៖

១. មួយថ្ងៃៗ សិស្សទាំងអស់ចាប់ផ្តើមជាមួយ ភ្លើង**បៃតង**
២. **លើកទីមួយ៖** ផ្តល់ការព្រមានបើសិនជាសិស្សមិនធ្វើតាមវិន័យក្នុងថ្នាក់
៣. **លើកទីពីរ៖** ផ្តល់ការព្រមានលើកទីពីរ ហើយដាក់ឈ្មោះសិស្សត្រង់ ភ្លើង**លឿង**។ គ្រូអាចដាក់វិន័យដល់សិស្សនៅក្នុងថ្នាក់ ឲ្យនៅតែឯង
៤. **លើកទីបី៖** បើសិនជាសិស្សនៅតែបន្តអាកប្បកិរិយាបែបនេះទៀត ផ្តល់ការព្រមានលើកទីបី ហើយដាក់ឈ្មោះសិស្សត្រង់ ភ្លើង**ក្រហម**។ ទូរស័ព្ទទៅមាតាបិតា និយាយអំពី អាកប្បកិរិយាដែលគេមិនចង់បាន និងការដាក់ទណ្ឌកម្មនៅថ្ងៃមុខ បើសិនជាសិស្សនៅតែបន្តអាកប្បកិរិយាបែបនេះតទៅទៀត។
៥. **លើកទីបួន៖** ប្រគល់លិខិត EH-20 (pink slip) ទៅនាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់ ជាបន្ទាន់។

ការដាក់វិន័យតាម លិខិត EH-20 រួមមាន តែគ្មានកំណត់ចំពោះអ្វីៗខាងក្រោមនេះ៖

- ជួបប្រជុំជាមួយមាតាបិតា
- សំបុត្របញ្ឈប់សិស្ស ដែលមាតាបិតាត្រូវមកជួបប្រជុំជាបន្ទាន់
- ការឃាត់ខ្លួនសិស្សទុកនៅពេលញ៉ាំអាហារថ្ងៃត្រង់
- ការដាក់ទណ្ឌកម្មឲ្យនៅក្នុងសាលា
- ថ្នាក់សម្រាប់ការធ្វើអន្តរាគមន៍លើអាកប្បកិរិយា
- ការបញ្ជូនទៅ RtII សម្រាប់អាកប្បកិរិយា

វិធីសាស្ត្រដែលគេបានយល់ព្រមសម្រាប់ថ្នាក់ខ្ពស់៖
ចំពោះការល្មើសច្បាប់អ្វីមួយនៃ បទល្មើសកម្រិត១ គ្រូត្រូវធ្វើតាមវិធីដាក់ទណ្ឌកម្មតាមលំដាប់ដូចតទៅ ដើម្បីដោះស្រាយអាកប្បកិរិយាដែលសិស្សបានប្រព្រឹត្ត៖

១. **លើកទីមួយ៖** គ្រូនឹងនិយាយអំពីអាកប្បកិរិយានេះ ជាមួយសិស្សដោយមិនឆេវឆាវ និងដោយស្ងាត់ៗ
២. **លើកទីពីរ៖** ដាក់វិន័យឲ្យសិស្សនៅតែឯង (ក្នុងបន្ទប់ ឬជាមួយគ្រូដែលរួមសហការ)។
៣. **លើកទីបី៖** ប្រជុំជាមួយសិស្ស
៤. **លើកទីបួន៖** មុន/ក្រោយពេល ឃាត់ខ្លួនសិស្សឲ្យនៅសាលា (គេនឹងជម្រាបទៅ មាតាបិតា/អាណាព្យាបាល)
៥. **លើកទីប្រាំ៖** ប្រគល់លិខិត EH-20 (pink slip) ទៅនាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់ ជាបន្ទាន់។

ការដាក់វិន័យតាម លិខិត EH-20 រួមមាន តែគ្មានកំណត់ទៅនឹងអ្វីៗខាងក្រោមនេះ៖
- ជួបប្រជុំជាមួយមាតាបិតា
- សំបុត្របញ្ឈប់សិស្ស ដែលមាតាបិតាត្រូវមកជួបប្រជុំជាបន្ទាន់
- បន្ថែមការឃាត់ខ្លួនសិស្សឲ្យនៅសាលា មុន/ក្រោយ ម៉ោងរៀន
- ការដាក់ទណ្ឌកម្មឲ្យនៅក្នុងសាលា
- ថ្នាក់សម្រាប់ការធ្វើអន្តរាគមន៍លើអាកប្បកិរិយា
- ការបញ្ជូនទៅ RtII សម្រាប់អាកប្បកិរិយា

**បទល្មើសកម្រិត១ ដែលអាចក្លាយជាបទល្មើសកម្រិត២**
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ចាត់ទុកអាកប្បកិរិយាដែលនាំឲ្យរំខានខាងក្រោមនេះជាបទល្មើសកម្រិត១ ដែលអាចក្លាយទៅជាបទល្មើសកម្រិត២ ទៅតាមការសម្រេចរបស់នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់។

- *វាយតប់គ្នា ទៅវិញទៅមក (ដោយគ្មាន របួសធ្ងន់ធ្ងរដល់រាងកាយ)*
- *ក្លែងបន្លំហត្ថលេខា របស់ រដ្ឋបាល គ្រូបង្រៀន ឬ មាតាបិតា / អាណាព្យាបាល*

វិធីសាស្ត្រដែលគេបានយល់ព្រម
ប្រគល់លិខិត EH-20 (pink slip) ទៅនាយកសាលា និង/ឬ អ្នកតំណាងជាបន្ទាន់។ សិស្សនឹងទទួលការដាក់ទណ្ឌកម្មម្តង ឬលើសពីម្តង តាមការយល់ព្រមសម្រាប់បទល្មើសកម្រិត១ ដូចបានរៀបរាប់ខាងលើនេះ ព្រមទាំងការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលា ពីមួយថ្ងៃ ទៅដប់ថ្ងៃ បើសិនជាបទល្មើសត្រូវបាននាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់ ចាត់ទុកថាជាបទល្មើសកម្រិត២។

**បទល្មើសកម្រិត១ ដែលអាចក្លាយជាបទល្មើសកម្រិត៣**
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ចាត់ទុកអាកប្បកិរិយាដែលនាំឲ្យរំខានខាងក្រោមនេះជាបទល្មើសកម្រិត១ ដែលអាចក្លាយទៅជាបទល្មើសកម្រិត២ ឬ៣ ទៅតាមការសម្រេចរបស់នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់។

- *បំផ្លាញ និង/ឬ លួច ទ្រព្យសម្បត្តិ (តិចជាង ៥០០$)*
- *ការសេពមេថុន (មានការយល់ព្រម)*

វិធីដែលគេបានយល់ព្រម
ប្រគល់លិខិត EH-20 (pink slip) ទៅនាយកសាលា និង/ឬ អ្នកតំណាងជាបន្ទាន់។ សិស្សនឹងទទួលការដាក់ទណ្ឌកម្មម្តង ឬលើសពីម្តង តាមការយល់ព្រមសម្រាប់បទល្មើសកម្រិត១ ដូចបានរៀបរាប់ខាងលើនេះ ព្រមទាំងការដាក់ទណ្ឌកម្មដូចតទៅ បើសិនជាបទល្មើសត្រូវបាន នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់ ចាត់ទុកថាជាបទល្មើសកម្រិត ២ ឬ៣៖

- ការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលា ពីមួយថ្ងៃ ទៅដប់ថ្ងៃ និង/ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់កិច្ចសន្យាជាមួយការធ្វើអន្តរាគមន៍ ឬការផ្លាស់ប្តូរសាលា។

**បទល្មើសកម្រិត១ ដែលអាចក្លាយជាបទល្មើសកម្រិត៤**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ចាត់ទុកអាកប្បកិរិយាដែលនាំឲ្យរំខានខាងក្រោមនេះជាបទល្មើសកម្រិត១ ដែលអាចក្លាយទៅជាបទល្មើសកម្រិត២ ៣ ឬ ៤ ទៅតាមការសម្រេចរបស់នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់៖

- *ការក្លែងបន្លំ របាយការណ៍ពិន្ទុ លិខិតសុំច្បាប់ឈប់ និង/ឬ ឯកសារសាលា*

វិធីសាស្ត្រដែលគេបានយល់ព្រម

ប្រគល់លិខិត EH-20 (pink slip) ទៅនាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់។ សិស្សនឹងទទួលការដាក់ទណ្ឌកម្មម្តង ឬលើសពីម្តង តាមការយល់ព្រមសម្រាប់បទល្មើសកម្រិត១ ដូចបានរៀបរាប់ខាងលើនេះ ព្រមទាំងការដាក់ទណ្ឌកម្មដូចតទៅ បើសិនជាបទល្មើសត្រូវបាន នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់ ចាត់ទុកថាជាបទល្មើសកម្រិត២ ៣ ឬ៤៖

- ការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលា ពីមួយថ្ងៃ ទៅដប់ថ្ងៃ និង/ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់កិច្ចសន្យាជាមួយការធ្វើអន្តរាគមន៍ ឬការផ្លាស់ប្តូរសាលា ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល ឲ្យផ្លាស់ទៅសាលាដែលមានវិន័យតឹងតែង (សម្រាប់ថ្នាក់ទី៦ ដល់ទី៨ តែប៉ុណ្ណោះ)។

**បទល្មើសកម្រិត១ ដែលអាចក្លាយជាបទល្មើសកម្រិត៥**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានចាត់ទុកអាកប្បកិរិយាដែលនាំឲ្យរំខានខាងក្រោមនេះជាបទល្មើសកម្រិត១ ដែលអាចក្លាយទៅជាបទល្មើសកម្រិត២ កម្រិត៣ កម្រិត៤ ឬ កម្រិត៥ ទៅតាមការសម្រេចរបស់នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់៖

- *ការប្រើគ្រឿងអេឡិចត្រូនិចដែលមិនសមរម្យ*
- *ការយាយី (រួមទាំង ការយាយីផ្លូវភេទ)*
- *ការសម្លុតធ្វើបាប/ការសម្លុតធ្វើបាបតាមគ្រឿងអេឡិចត្រូនិច*
- *ការគម្រាមកំហែង*

វិធីសាស្ត្រដែលគេបានយល់ព្រម

ត្រូវប្រគល់ លិខិត EH-20 (លិខិតពណ៌ផ្កាឈូក) ទៅនាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់។ សិស្សនឹងទទួលទណ្ឌកម្មមួយ ឬលើសពីនេះ ដែលគេបានយល់ព្រមសម្រាប់បទល្មើសកម្រិត១ ដូចបានរៀបរាប់ខាងលើនេះ ព្រមទាំងការដាក់វិន័យបន្ថែមទៀត ដូចតទៅនេះ បើសិនជាបទល្មើសត្រូវបានគេចាត់ទុកថាជាបទល្មើសកម្រិត២ ៣ ឬ ៤ ដោយនាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់៖

- ការបញ្ឈប់បណ្តោះអាសន្នមិនឲ្យមកសាលា ពីមួយថ្ងៃ ទៅដប់ថ្ងៃ និង/ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់កិច្ចសន្យាជាមួយការធ្វើអន្តរាគមន៍ ឬការផ្លាស់ប្តូរសាលា ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់បញ្ជូនទៅសាលាដែលមានវិន័យតឹងតែង (សម្រាប់ថ្នាក់ទី៦ ដល់ថ្នាក់ទី៨ តែប៉ុណ្ណោះ) និង/ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់ការបណ្តេញចេញពីសាលា។

**បទល្មើសកម្រិត២ ដែលអាចក្លាយជាបទល្មើសកម្រិត៤**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានចាត់ទុកអាកប្បកិរិយាដែលនាំឲ្យរំខានខាងក្រោមនេះជាបទល្មើសកម្រិត២ ដែលអាចក្លាយទៅជាបទល្មើសកម្រិត៣ ឬ៤ ទៅតាមការសម្រេចរបស់នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់៖

- *គម្រាមកំហែងដល់ សិស្ស/បុគ្គលិក ថានឹងវាយតប់គេយ៉ាងធ្ងន់ធ្ងរ*
- *បំផ្លាញ និង/ឬ លួចទ្រព្យសម្បត្តិ* (ចំនួន ៥០០$ ឬច្រើនជាងនេះ)
- *វាយបំបាក់ ហើយចូលក្នុងសាលា*
- *វាយតប់គ្នាទៅវិញទៅមក* (មានឯកសារបញ្ជាក់ថាមានរបួសធ្ងន់ធ្ងរដល់រាងកាយ)
- *វាយតប់គេ*

វិធីសាស្ត្រដែលគេបានយល់ព្រម៖
ចំពោះការល្មើសច្បាប់អ្វីមួយនៃផ្នែកខាងលើនេះ សិស្សនឹងទទួលការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលាពីមួយថ្ងៃ ទៅដប់ថ្ងៃ បន្ថែមលើ៖

- ការបញ្ជូនទៅ RtII សម្រាប់អាកប្បកិរិយា
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់កិច្ចសន្យាជាមួយការធ្វើអន្តរាគមន៍ ឬការផ្លាស់ប្តូរសាលា ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល ឲ្យផ្លាស់ទៅសាលាដែលមានវិន័យតឹងតែង (សម្រាប់ថ្នាក់ទី៦ ដល់ទី៨ តែប៉ុណ្ណោះ)។

**បទល្មើសកម្រិត២ ដែលអាចក្លាយជាបទល្មើសកម្រិត៥**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានចាត់ទុកអាកប្បកិរិយាដែលនាំឲ្យរំខានខាងក្រោមនេះជាបទល្មើសកម្រិត២ ដែលអាចក្លាយទៅជាបទល្មើសកម្រិត៣ ៤ ឬ ៥ ទៅតាមការសម្រេចរបស់នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់៖

- *ការលួចប្លន់*
- *ការជម្រិតយកប្រាក់*
- *មានគ្រឿងស្រវឹង និង/ឬ គ្រឿងញៀន*
- *ការបង្កឲ្យមានគ្រោះថ្នាក់*
- *ការសេពមេថុន* (គ្មានការយល់ព្រម)
- *មាន ឬប្រើ កាំភ្លើច / គ្រឿងផ្ទុះផ្សេងៗ / គ្រឿងឆេះ*
- *វាយតប់សមាជិកនៃបុគ្គលិកសាលា*
- *នាំរឿង និង/ឬ ចូលរួមក្នុងក្រុមដើរវាយតប់គេ*

វិធីសាស្ត្រដែលគេបានយល់ព្រម៖
ចំពោះការល្មើសច្បាប់អ្វីមួយនៃផ្នែកខាងលើនេះ សិស្សនឹងទទួលការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលាពីមួយថ្ងៃ ទៅដប់ថ្ងៃ បន្ថែមលើ៖

- ការបញ្ជូនទៅ RtII សម្រាប់អាកប្បកិរិយា
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់កិច្ចសន្យាជាមួយការធ្វើអន្តរាគមន៍ ឬការផ្លាស់ប្តូរសាលា ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល ឲ្យផ្លាស់ទៅសាលាដែលមានវិន័យតឹងតែង (សម្រាប់ថ្នាក់ទី៦ ដល់ទី៨ តែប៉ុណ្ណោះ) និង/ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល ឲ្យបណ្តេញចេញ។

**បទល្មើសកម្រិត៣ ដែលអាចក្លាយជាបទល្មើសកម្រិត៥**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានចាត់ទុកអាកប្បកិរិយាដែលនាំឲ្យរំខានខាងក្រោមនេះជាបទល្មើសកម្រិត៣ ដែលអាចក្លាយទៅជាបទល្មើសកម្រិត៤ ឬ ៥ ទៅតាមការសម្រេចរបស់នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់៖

- *វាយតប់គេ*

វិធីសាស្រ្តដែលគេបានយល់ព្រម៖

ចំពោះបទល្មើសខាងលើនេះ សិស្សនឹងទទួលការបញ្ឈប់បណ្តោះអាសន្នមិនឲ្យមកសាលា ពីមួយថ្ងៃ ទៅដប់ថ្ងៃ បន្ថែមលើ៖

- ការបញ្ជូនទៅ RtII សម្រាប់អាកប្បកិរិយា
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់កិច្ចសន្យាជាមួយការធ្វើអន្តរាគមន៍ ឬការផ្លាស់ប្តូរសាលា ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល ឲ្យផ្លាស់ទៅសាលាដែលមានវិន័យតឹងតែង (សម្រាប់ថ្នាក់ទី៦ ដល់ទី៨ តែប៉ុណ្ណោះ) និង/ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល ឲ្យបណ្តេញសិស្សចេញពីសាលា។

**បទល្មើសកម្រិត៤ ដែលអាចក្លាយជាបទល្មើសកម្រិត៥**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បានចាត់ទុកអាកប្បកិរិយាដែលនាំឲ្យរំខានខាងក្រោមនេះជាបទល្មើសកម្រិត៤ ដែលអាចក្លាយទៅជាបទល្មើសកម្រិត៥ ទៅតាមការសម្រេចរបស់នាយកសាលា និង/ឬ អ្នកតំណាងរបស់គាត់៖

- *មានអាវុធ*

វិធីសាស្រ្តដែលគេបានយល់ព្រម៖

ចំពោះការល្មើសច្បាប់អ្វីមួយនៃផ្នែកខាងលើនេះ សិស្សនឹងទទួលការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលាពីមួយថ្ងៃ ទៅដប់ថ្ងៃ បន្ថែមលើ៖

- ការបញ្ជូនទៅ RtII សម្រាប់អាកប្បកិរិយា
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល សម្រាប់កិច្ចសន្យាជាមួយការធ្វើអន្តរាគមន៍ ឬការផ្លាស់ប្តូរសាលា ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល ឲ្យផ្លាស់ទៅសាលាដែលមានវិន័យតឹងតែង (សម្រាប់ថ្នាក់ទី៦ ដល់ទី៨ តែប៉ុណ្ណោះ) និង/ឬ
- ការបញ្ជូនទៅ ការិយាល័យផ្នែក សវនាការ និងបណ្តេញសិស្សចេញពីសាលា ដោយមានសំណូមពរពីរដ្ឋបាល ឲ្យបណ្តេញចេញ។

**ក. ការឃាត់ខ្លួន**

ការឃាត់ខ្លួន មុនម៉ោងចូលរៀន នៅពេលញុំាអាហារថ្ងៃត្រង់ និងក្រោយម៉ោងរៀន អាចអនុវត្តសម្រាប់បទល្មើសកម្រិត១។ គេតម្រូវឲ្យសិស្សមកកាន់កន្លែងដែលគេឃាត់ខ្លួនឲ្យបានទាន់ម៉ោង ព្រមទាំងយកសម្ភារៈសម្រាប់សិក្សាមកជាមួយផង។ សិស្សត្រូវរក្សាការស្ងៀមស្ងាត់ ប៉ុន្តែហាមមិនឲ្យគេង។ សិស្សត្រូវរៀនពីក្រមសីលធម៌ ក្នុងពេលដែលត្រូវគេឃាត់ខ្លួន។ សិស្សានុសិស្សដែលមិនមកកន្លែងឃាត់ខ្លួនតាមការដាក់វិន័យ ឬដែលត្រូវគេឃាត់ខ្លួនច្រើនដងហួសហេតុ នឹងត្រូវទទួលការដាក់ទណ្ឌកម្មមួយកម្រិតថែមទៀត។

**ខ. ការបញ្ឈប់បណ្តោះអាសន្ននៅក្នុងសាលា** (ISS)

សិស្សានុសិស្សដែលឈានដល់បញ្ហានៃវិធានការដាក់វិន័យបែបនេះ នឹងដាក់នៅក្នុងបន្ទប់គ្រូទទួលបន្ទុកណាម្នាក់ សម្រាប់រយៈពេលពេញមួយថ្ងៃ។ សិស្សនឹងទទួលកិច្ចការរបស់ថ្នាក់រៀន ពីគ្រូរបស់ខ្លួននៅពេលព្រឹក ហើយទៅកាន់ថ្នាក់រៀនដែលគេតម្រូវឲ្យទៅ ហើយអង្គុយនៅខាងក្រោយថ្នាក់រៀននោះ ធ្វើកិច្ចការទាំងអស់ឲ្យហើយដោយស្ងាត់ស្ងៀម និងដោយការគោរព។ សិស្សនឹងទៅតាមថ្នាក់នេះក្នុងរយៈពេលពេញមួយថ្ងៃ ហើយមិនអនុញ្ញាតឲ្យចូលរួមក្នុងថ្នាក់ តាមកាលវិភាគដែលខ្លួនត្រូវរៀននោះទេ។ សិស្សណាដែលធ្វើមិនបានតាមការចង់បានរបស់ ISS នឹងទទួលការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលាអស់រយៈពេលមួយថ្ងៃដោយស្វ័យប្រវត្ត។

**គ. ការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលា**

គោលបំណងនៃការបញ្ឈប់បណ្តោះអាសន្នឲ្យនៅក្រៅសាលា**គឺដើម្បីឲ្យ សិស្ស និងមាតាបិតា ដឹងថាសិស្សមានអាកប្បកិរិយាដែលធ្វើឲ្យរំខាន ដែលគេមិនទទួលស្គាល់ និងមានភាពធ្ងន់ធ្ងរ។ ហេតុដូច្នេះ បើសិនជាសិស្សត្រូវគេបញ្ឈប់បណ្តោះអាសន្ន គេនឹងអនុញ្ញាតឲ្យសិស្សត្រឡប់មករៀនវិញ តែក្នុងករណីក្រោយពេលដែលមាតាបិតា ឬអាណាព្យាបាលរបស់ពួកគេបានជួបជាមួយ** Mr. Lukov និង/ឬ អ្នកតំណាងរបស់គាត់។ **គេមិនអនុញ្ញាតឲ្យ បងប្អូនប្រុស បងប្អូនស្រី មីង មា និង សាច់ញាតិដទៃទៀតមកសុំឲ្យសិស្សដែលគេបញ្ឈប់បណ្តោះអាសន្ននេះ ត្រឡប់មករៀនវិញបានទេ លើកលែងតែពួកគេជាអាណាព្យាបាល។ ជាបន្ថែមទៀត គេមិនទទួលការស្នើសុំឲ្យសិស្សត្រឡប់មករៀនវិញតាមទូរស័ព្ទទេ។**

គេមិនអនុញ្ញាតឲ្យសិស្សានុសិស្សដែលត្រូវបានបញ្ឈប់បណ្តោះអាសន្នចូលក្នុងអាគារ ឬទីធ្លាសាលាទេ។ ហើយមិនអាចចូលរួមក្នុងសកម្មភាពសាលាអ្វីមួយបានទេ រួមទាំងកម្មវិធីក្រោយម៉ោងសិក្សា។ សិស្សានុសិស្សដែលត្រូវគេបញ្ឈប់បណ្តោះអាសន្ន ហើយមកកាន់ទីធ្លាសាលា ត្រូវគេចាត់ទុកថាជាការចូលក្នុងតំបន់ហាមឃាត់។ ការមិនគោរពធ្វើតាម នឹងបណ្តាលឲ្យមានការដាក់ទណ្ឌកម្មបន្ថែមទៀត។

**ឃ. វិធីផ្លាស់ប្តូរ**

សិស្សានុសិស្សថ្នាក់ទីប្រាំមួយ ដល់ទីប្រាំបី ដែលមានទម្លាប់អាកប្បកិរិយាដែលធ្វើឲ្យរំខាន និង/ឬ បទល្មើសធ្ងន់ធ្ងរលើក្រមសីលធម៌ នឹងត្រូវគេបញ្ជូនទៅ ការិយាល័យផ្នែក ដាក់វិន័យ សវនាការ និងបណ្តេញសិស្សចេញពីសាលា។ សិស្សានុសិស្សដែលត្រូវគេបញ្ជូនទៅ នឹងទទួលសវនាការតាមច្បាប់នៃការគោរពសិទ្ធិរបស់បុគ្គល រួមទាំង សវនាការដើម្បីសម្រេចថាតើសិស្សត្រូវផ្លាស់ទៅសាលាដែលមានវិន័យតឹងតែងឬអត់។ សិស្សានុសិស្សដែលត្រូវគេបញ្ជូនទៅដើម្បីធ្វើសវនាការ នឹងត្រូវបញ្ឈប់ជាបណ្តោះអាសន្ន។ សិស្សានុសិស្សថ្នាក់មត្តេយ្យដល់ថ្នាក់ទី៥ មិនបាច់ធ្វើតាមវិធីផ្លាស់ប្តូរនេះទេ។ ពួកគេត្រូវបញ្ជូនតាមរយៈនៃវិធីឆ្លើយតបទៅនឹង ការបង្ហាត់បង្រៀន និងការធ្វើអន្តរាគមន៍ (RtII)។ ដំណាក់កាលទី៣ នៃវិធីនេះ រួមទាំងការបញ្ជូនទៅវិទ្យាស្ថាន Crossroads ដែលជាកន្លែងគ្រប់គ្រងដោយក្រសួងអប់រំ សម្រាប់សិស្សានុសិស្សដែលត្រូវគេបញ្ជូនទៅតាមរយៈវិធី RtII ដែលផ្តល់កម្មវិធី សិក្សា សង្គមកិច្ច និង ការពង្រឹងផ្លូវចិត្ត។